# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/៧៦៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា"
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា"
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

# ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានកែសំរួលមាត្រា៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា" ដូចតទៅ :

**មាត្រា៤ថ្មី.-**

អាជ្ញាធរ "អប្សរា" ត្រូវស្ថិតនៅក្រោមការដឹកនាំនៃទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្នុងឋានៈនេះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" និងកាន់មុខតំណែងជាប្រធានអាជ្ញាធរ "អប្សរា" ។

ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" មានសមាសភាពដូចតទៅ :

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - តំណាងអាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| - តំណាងសាលាខេត្តសៀមរាប | សមាជិក |
| - តំណាងបុគ្គលិកអាជ្ញាធរ "អប្សរា" | សមាជិក |

**មាត្រា៥ថ្មី.-**

ប្រធានអាជ្ញាធរ "អប្សរា" មានសិទ្ធិអំណាចដូចមានចែងនៅក្នុងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមានតួនាទី និងភារកិច្ចបន្ថែមដូចតទៅ :

- តំណាងរាជរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ គ្រប់ពិធី និងគ្រប់ការចរចាដែលពាក់ព័ន្ធនឹងតំបន់រមណីយ-ដ្ឋានអង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀត
- មានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀង លើពិធីសារ លើកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀត
- ជាអាណាប័កដើមខ្សែនៃអាជ្ញាធរ "អប្សរា" និងជាអ្នកពិនិត្យចំណូលប្រាក់ ទូទាត់ចំណូល ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ
- អាចផ្ទេរសិទ្ធិអោយអាណាប័កផ្ទេរសិទ្ធិ ឬបង្កើតអោយមានការព្រមព្រៀងជាគណនេយ្យករទូទាត់ទទួលចំណូល ឬបុរេប្រទាន

ប្រធានអាជ្ញាធរ "អប្សរា" មានជំនួយការជាអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនទៀតដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា២.-**

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្ដីទី**

៣រស.០៤០៩.២៦៩

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ: ២២២ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**